ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៣៩១២......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យបន្តលើកទី៣ សម្រាប់ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតនៅក្នុងភូមិសាស្ត្រត្រូវជាប់ពន្ធលើអចលនទ្រព្យនៃរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារនៅពិនិត្យឃើញថា ក្នុងអំឡុងពេលពន្យារការប្រមូលពន្ធលើអចលនទ្រព្យកន្លងមកនេះ មានម្ចាស់អចលនទ្រព្យជាច្រើនបានមកប្រកាសបង់ពន្ធ និងមានម្ចាស់អចលនទ្រព្យមួយចំនួនតូចទៀតនៅមិនទាន់បានមកប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤នៅឡើយ។

ដោយអគ្គនាយកដ្ឋានពន្ធដារបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យពន្យារពេលប្រកាសបង់លើអចលនទ្រព្យបន្តលើកទី៣ទៀត រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីទុកលទ្ធភាពឱ្យម្ចាស់អចលនទ្រព្យដែលមិនទាន់បានបង់ពន្ធមានពេលវេលាគ្រប់គ្រាន់មកប្រកាសបង់ពន្ធនេះ។

ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួល និងឆាប់រហ័សដល់ម្ចាស់អចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារបាន និងបន្តឱ្យម្ចាស់អចលនទ្រព្យមកប្រកាសបង់ពន្ធនេះនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអចលនទ្រព្យតាំងនៅ ឬនៅតាមធនាគារ អេស៊ីលីដា ភីអិលស៊ី ឬធនាគារ កាណាឌីយ៉ា ក.អ ណាមួយដែលស្ថិតនៅជិតលោក-អ្នក។

ក្នុងករណីម្ចាស់អចលនទ្រព្យទាំងឡាយដែលមិនទាន់បានមកប្រកាសបង់ពន្ធលើអចលនទ្រព្យ ឬមកប្រកាសបង់ពន្ធក្រោយការពន្យារពេលខាងលើ នឹងត្រូវរងទោសទណ្ឌក្នុងការបង់ប្រាក់ពន្ធផង និងបង់ប្រាក់ផាកពិន័យផង ស្របតាមច្បាប់ស្តីពីសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ មានក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអំឡុងពេលពន្យារនេះ ម្ចាស់អចលនទ្រព្យទាំងអស់នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា តាមការកំណត់នេះជាក់ជាពុំខាន។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល